ការពង្រឹងភាពធន់ទៅនឹងរលកកម្តៅខ្លាំងនៅរាជធានីភ្នំពេញ៖

ធានាសហគមន៍ក្នុងទីក្រុងមានសុវត្ថិភាព មានសុខភាពល្អ និងប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា

គម្រោងនេះកំពុងស្ថិតក្រោមការរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. សម្រាប់ការស្នើសុំហិរញ្ញប្បទានពីមូលនិធិអាកាសធាតុបៃតង (GCF)

សង្ខេប

រាជធានីភ្នំពេញ កំពុងប្រឈមមុខកាន់តែខ្លាំងទៅនឹងរលកកម្តៅក្តៅខ្លាំង ដោយសារនគរូបនីយកម្មយ៉ាងឆាប់រហ័ស និងការប្រែប្រួលអាកាសធាតុ។ គ្រួសារក្រីក្រដែលរស់នៅក្នុងតំបន់សហគមន៍ក្រីក្រក្រោមដំបូលស័ង្កសី មនុស្សចាស់ កុមារ ស្ត្រីមានផ្ទៃពោះ និងអ្នកធ្វើការងារខាងក្រៅអគារ គឺជាអ្នកដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ។ ប្រព័ន្ធអគ្គិសនី និងប្រព័ន្ធសុខាភិបាលរបស់ទីក្រុង ដែលមិនត្រូវបានរៀបចំឡើងសម្រាប់ទប់ទល់នឹងរលកកម្តៅខ្លាំងតែងតែជួបប្រទះតម្រូវការការប្រើប្រាស់ច្រើនលើសលប់នៅរដូវក្តៅ។ ទោះបីជាមានវឌ្ឍនភាពក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយក៏ដោយ ប៉ុន្តែប្រទេសកម្ពុជានៅខ្វះប្រព័ន្ធដែលមានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់ការតាមដាន ការប្រកាសឱ្យដឹងមុន និងការសម្របសម្រួលដើម្បីឆ្លើយតបចំពោះរលកកម្តៅ។

ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈលេខាធិការដ្ឋានរបស់ខ្លួន កំពុងសហការជាមួយ GIZ ដើម្បីរៀបចំសំណើគម្រោងដាក់ជូនមូលនិធិអាកាសធាតុបៃតង (GCF)។ ក្នុងនាមជាអង្គភាពថ្នាក់ជាតិដែលជាស្ថាប័នទទួលមូលនិធិផ្ទាល់ពី GCF លេខាធិការដ្ឋាន គ.ជ.អ.ប. មានគោលបំណងកៀរគរហិរញ្ញប្បទានអាកាសធាតុ ដើម្បីពង្រឹងភាពធន់របស់រាជធានីភ្នំពេញទៅនឹងរលកកម្តៅខ្លាំង។ គម្រោងដែលបានពណ៌នានៅក្នុងឯកសារនេះ មានគោលបំណងបង្កើតអភិក្រមសាកល្បង ដើម្បីពង្រឹងភាពធន់អោយបានទូលំទូលាយទៅនឹងរលកកម្តៅនៅក្នុងរាជធានីភ្នំពេញ។ គម្រោងនេះនឹងពង្រឹងការតាមដានកម្តៅ និងការប្រកាសឱ្យដឹងមុនតាមរយៈស្ថាបត្យកម្មទិន្នន័យសម្រាប់ការតាមដានមើលកម្តៅ ព្រមទាំងគាំទ្រដល់ក្រសួងធនធានទឹក និងឧតុនិយម និងរដ្ឋបាលរាជធានីភ្នំពេញ ក្នុងការរៀបចំផែនការសកម្មភាពកម្តៅរាជធានីភ្នំពេញ (PP-HAP) ដែលមានការកំណត់ច្បាស់នូវកម្រិតកំណត់ពិធីសារ និងការទទួលខុសត្រូវ។ គ្រួសារ និងសហគមន៍ងាយរងគ្រោះ នឹងទទួលបានការគាំទ្រ តាមរយៈប្រព័ន្ធគាំពារសង្គមថ្នាក់ជាតិ ខណៈដែលសាលារៀន ខ្លឹនិកសុខភាព និងមូលដ្ឋានសុខាភិបាល ព្រមទាំងទីតាំងសង្គមផ្សេងទៀតនៅក្នុងបណ្តាខណ្ឌអាទិភាព នឹងត្រូវបានបំពាក់បន្ថែមនូវដំណោះស្រាយលើការកាត់បន្ថយកម្តៅបែបអសកម្ម ឬបែបធម្មជាតិ និងតាមបែបប្រើប្រាស់ថាមពលត្រជាក់ប្រកបដោយប្រសិទ្ធភាព។ បន្ថែមលើនេះ យន្តការហិរញ្ញប្បទានផ្អែកលើការព្យាករណ៍នឹងបញ្ចេញមូលនិធិ ដែលបានរៀបចំទុកជាមុន និងជំរុញឱ្យមានសកម្មភាពឆ្លើយតបជាមុន រួមទាំងនៅក្នុងវិស័យសុខាភិបាល ខណៈដែលកម្មវិធីនិយោគសាធារណៈរបស់រាជធានីភ្នំពេញនឹងចាប់ផ្តើមបម្រុងទុកធនធានសម្រាប់ការកាត់បន្ថយរលកកម្តៅទីក្រុងក្នុងរយៈពេលវែង។

បញ្ហាប្រឈម

ការប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្តៅ

រាជធានីភ្នំពេញកំពុងប្រឈមមុខនឹងនិន្នាការនៃការកើនឡើងកម្តៅគួរឱ្យកត់សម្គាល់ ដោយទិន្នន័យតាំងពីឆ្នាំ២០១០មក បានបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃចំនួនថ្ងៃ ដែលសន្ទស្សន៍កម្តៅបានហក់ឡើងលើស ៣៥ អង្សាសេ[1]។ ការរួមបញ្ចូលគ្នារវាងសីតុណ្ហភាពខ្យល់ និងសំណើម គឺជាសន្ទស្សន៍កម្រិតកម្តៅ ដែលមនុស្សមានអារម្មណ៍ជាក់ស្តែង ដែលជាទូទៅគឺ ខ្ពស់ជាងសីតុណ្ហភាពពិតប្រាកដ។ យោងតាមការព្យាករណ៍អាកាសធាតុនាពេលអនាគត ការកើនឡើងកម្តៅបែបនេះរំពឹងថានឹងនៅតែបន្ត។ ប្រទេសកម្ពុជាអាចនឹងជួបប្រទះការកើនឡើងសីតុណ្ហភាពរហូតដល់ ២,៦ អង្សាសេ នៅអំឡុងឆ្នាំ២០៤១-២០៧០ និង ៣,៦ អង្សាសេ នៅឆ្នាំ២០៩០ ក្រោមសេណារីយ៉ូ RCP8.5[2] ដោយសាររលកកម្តៅនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ជាទូទៅត្រូវបានគេរំពឹងថា នឹងកើនឡើងញឹកញាប់ មានរយៈពេលវែង និងមានស្ថានភាពធ្ងន់ធ្ងរជាងមុន។ បន្ថែមលើសពីនេះ ការកើនឡើងសីតុណ្ហភាព នឹងបណ្តាលឱ្យសំណើមកើនឡើង និងសម្ពាធដោយសារកម្តៅ (heat stress) កាន់តែធ្ងន់ធ្ងរ ដែលបង្កហានិភ័យកាន់តែខ្លាំងដល់សុខុមាលភាពរបស់មនុស្សជាតិ[3]។

ផលប៉ះពាល់នៃរលកកម្តៅ

បច្ចុប្បន្នប្រទេសកម្ពុជាបាននិងកំពុងទទួលរងឥទ្ធិពលរលកកម្តៅ និងការប្រែប្រួលអាកាសធាតុកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ[4] ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព ជីវភាពរស់នៅ និងសុខុមាលភាពទូទៅរបស់ប្រជាជន។ រលកកម្តៅបង្កើនហានិភ័យដូចជា អាការៈអស់កម្លាំង ខ្យល់គរ ឬសន្លប់[5] (Heat stroke) រួមទាំងជំងឺប្រព័ន្ធសរសៃឈាម បេះដូង ផ្លូវដង្ហើម[6] និងការស្លាប់បាត់បង់ជីវិតផងដែរ[7]។ ផលប៉ះពាល់ទាំងនេះមានសភាពធ្ងន់ធ្ងរ ជាពិសេសចំពោះកុមារ[8] មនុស្សវ័យចាស់[9] ស្ត្រី អ្នកមានជំងឺរ៉ាំរ៉ៃ និងជនមានពិការភាព ដែលបង្កឱ្យមានអត្រាអ្នកជំងឺកាន់តែច្រើន[10]។ អ្នកធ្វើការងារនៅក្រៅអគារ និងអ្នករស់នៅក្នុងតំបន់សហគមន៍ក្រីក្រច្រើនតែប្រឈមនឹងឥទ្ធិពលរលកកម្តៅរយៈពេលយូរ ដោយខ្វះវិធានការការពារគ្រប់គ្រាន់ ដែលទាំងឱ្យផលិតភាពការងារធ្លាក់ចុះ និងបង្កើនគ្រោះថ្នាក់ក្នុងពេលបំពេញការងារ[11]។ នៅរាជធានីភ្នំពេញ កត្តាផ្សេងទៀតក្រៅពីការប្រែប្រួលអាកាសធាតុ ដូចជា កម្តៅតំបន់ទីក្រុង (UHI) កាន់តែធ្វើឱ្យមានហានិភ័យរលកកម្តៅកើនឡើង ហើយសីតុណ្ហភាពពេលថ្ងៃនៅទីក្រុង និងជនបទ អាចខុសគ្នារហូតដល់ ៤ អង្សាសេ[12]។ កត្តាសេដ្ឋកិច្ច-សង្គម រួមទាំងភាពក្រីក្រ និងគុណភាពលំនៅឋានមិនសមរម្យ ព្រមទាំងសមត្ថភាពរបស់ប្រជាជនក្នុងការទប់ទល់នឹងរលកកម្តៅខ្លាំងនៅមានកម្រិតផងដែរ។ ក្នុងហានៈជាប្រទេសកំពុងអភិវឌ្ឍ កម្ពុជាចាំបាច់ត្រូវការវិធានការបន្ទាំទៅនឹងការប្រែប្រួលអាកាសធាតុ និងសហការសម្របសម្រួលដោះស្រាយជាប់ទ្ធាន់ឱ្យបានទាន់ពេលវេលា។

[1] World Bank, Climate Change Knowledge Portal (2025). URL: https://climateknowledgeportal.worldbank.org/. Date Accessed: 22 June 2025
[2] World Bank Group. Climate Change Knowledge Portal: Cambodia.
[3] Wet-bulb temperature is a measure of heat stress that combines air temperature and humidity. It represents the lowest temperature that can be reached by evaporating water into the air at constant pressure. Essentially, it measures how effective a body is able to regulate itself through the evaporation of sweat.
[4] IPCC (2021). Sixth Assessment Report, Working Group I: The Physical Science Basis.
[5] Bouchama, A., Mündel, T., & Laitano, O. (2024). Beyond heatwaves: A nuanced view of temperature-related mortality. Temperature, 11(3), 190-202.
[6] Aghababaeian, H., Sharafkhani, R., Hamidipour, N., & Ahvazi, L. A. (2025). Analyzing cardiovascular disease hospitalization risks due to cold and heat waves in Dezful. Scientific reports, 15(1), 1-11.
[7] Ebi, K. L., Capon, A., Berry, P., Broderick, C., de Dear, R., Havenith, G., ... & Jay, O. (2021). Hot weather and heat extremes: health risks. The lancet, 398(10301), 698-708.
[8] Schapiro, Laura H., Mark A. McShane, Harleen K. Marwah, Megan E. Callaghan, and Mandy L. Neudecker. "Impact of extreme heat and heatwaves on children's health: a scoping review." The Journal of Climate Change and Health (2024): 100335.
[9] Åström, D. O., Bertil, F., & Joacim, R. (2011). Heat wave impact on morbidity and mortality in the elderly population: a review of recent studies. Maturitas, 69(2), 99-105.
[10] GHHIN Southeast Asia Hub. (2025). First GHHIN Southeast Asia Heat Health Forum - Summary Report. Global Heat Health Information Network (GHHIN). https://ghhin.org/2025-southeast-asia-heat-health-forum/
[11] GHHIN Southeast Asia Hub. (2025). First GHHIN Southeast Asia Heat Health Forum - Summary Report. Global Heat Health Information Network (GHHIN). https://ghhin.org/2025-southeast-asia-heat-health-forum/
[12] Climate Risk Profile: Cambodia (2021): The World Bank Group and Asian Development Bank.

Implemented by: giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH
Co-financed by: Australian Aid
កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT



រូបភាពទី ១៖ និន្នាការប្រចាំឆ្នាំនៃចំនួនថ្ងៃដែលមានសន្ទស្សន៍កម្តៅធំជាង ៣៥ អង្សាសេ រួមជាមួយនឹងនិន្នាការសំខាន់ៗក្នុងមួយទសវត្សរ៍ (១៩៥១-២០២៣) រាជធានីភ្នំពេញ[13]

ឥទ្ធិពលកម្តៅតំបន់ទីក្រុង

ឥទ្ធិពលកម្តៅតំបន់ទីក្រុង (Urban Heat Island - UHI) កើតឡើង នៅពេលដែលតំបន់ទីក្រុងមានកម្តៅក្តៅជាងតំបន់ជនបទ។ បញ្ហានេះកើតឡើងដោយសារតែអគារស្ពេកស្តុះមិនសូវមានរុក្ខជាតិបៃតង ផ្ទៃចាក់បេតុង កៅស៊ូ ដែលទាំងឱ្យមានការកើនកម្តៅ និងអូសបន្លាយពេលយូរជាងមុន ព្រោះការបន្តយកម្តៅតាមធម្មជាតិ ដូចជា ការផ្តល់ម្លប់ និងបរិយាកាសខ្យល់ចេញចូលត្រូវបានថយចុះ[14]។ នៅតំបន់អាស៊ីបូព៌ា ជាមធ្យម ទីក្រុងមានកម្តៅក្តៅជាងតំបន់ជនបទក្បែរខាង ចន្លោះពី ១,៦ ទៅ ២,០ អង្សាសេ[15]។ ជាលទ្ធផល ឥទ្ធិពលកម្តៅតំបន់ទីក្រុងនេះ បានធ្វើឱ្យរលកកម្តៅកាន់តែកើនឡើងធ្ងន់ធ្ងរ និងធ្វើឱ្យដងផ្លូវ ដំបូលអគារ និងលំហខាងក្នុងអគារកាន់តែក្តៅខ្លាំងសម្រាប់អ្នករស់នៅតំបន់ទីក្រុង ជាពិសេស ក្រុមជនងាយរងគ្រោះ និងសហគមន៍ក្រីក្រ ដែលភាគច្រើនរស់នៅក្នុងតំបន់ដែលមានរុក្ខជាតិបៃតងតិចតួច និងប្រពន្ធ័ការពារកម្តៅខ្សោយ។

ដោយសារតែឥទ្ធិពលកម្តៅតំបន់ទីក្រុង គឺជាបាតុភូតដែលកើតឡើងតាមតំបន់មូលដ្ឋានទីមួយៗ ដូច្នេះសកម្មភាពនៅកម្រិតទីក្រុងដែលត្រូវដោះស្រាយមានដូចជា ការបង្កើនគម្របបៃតង ការកែលម្អសំណង់ និងការរៀបចំទីធ្លាសាធារណៈឱ្យមានភាពត្រជាក់ជាងមុន អាចបង្កើតភាពខុសប្លែកគ្នាយ៉ាងពិតប្រាកដក្នុងការកាត់បន្ថយភាពតានតឹង ឬ សម្ពាធដោយសារកម្តៅ និងការបង្កើនជាសុខភាពសម្រាប់ការរស់នៅកាន់តែប្រសើរឡើង។

បញ្ហាប្រឈម និងកាលានុវត្តភាពសម្រាប់ពង្រឹងការត្រៀមលក្ខណៈឆ្លើយតបទឹងរលកកម្តៅ

គោលនយោបាយ និងស្ថាប័ន៖ កម្ពុជាសម្រេចបានវឌ្ឍនភាពយ៉ាងល្អក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ប៉ុន្តែក្របខណ្ឌដែលមានស្រាប់ភាគច្រើនផ្តោតលើទឹកជំនន់ និងគ្រោះរាំងស្ងួត។ បច្ចុប្បន្ន កម្ពុជាមានឱកាសក្នុងការលើកកម្ពស់ការសម្របសម្រួលអន្តរក្រសួង និងដាក់បញ្ចូលការត្រៀមលក្ខណៈឆ្លើយតបទឹងរលកកម្តៅទៅក្នុងប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងប្រព័ន្ធគាំពារសង្គម និងសេវាសាធារណៈ ជាពិសេស វិស័យសុខាភិបាល។

សេដ្ឋកិច្ចសង្គម៖ គ្រួសារជាច្រើនដែលរស់នៅទីក្រុង ជាពិសេសក្នុងតំបន់សហគមន៍ក្រីក្រ ជួបប្រទះនឹងឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជា ទីតាំងរស់នៅតូច អ៊ីសូឡង់ការពារកម្តៅខ្សោយ និងការរស់នៅមានភាពកកកុញ ដែលធ្វើឱ្យកាន់តែលំបាកដល់ការកាត់បន្ថយកម្តៅ។ រាល់ដំណោះស្រាយនានាត្រូវធានាថា សហគមន៍ក្រីក្រទាំងនេះ និងអ្នកផ្តល់សេវាថែទាំសុខភាព មិនត្រូវបានគេទុកចោល។

ព័ត៌មាន ការយល់ដឹង និងសមត្ថភាព៖ ប្រព័ន្ធព័ត៌មានអាកាសធាតុ និងរលកកម្តៅ កំពុងត្រូវបានកែលម្អឱ្យប្រសើរឡើង ប៉ុន្តែទិន្នន័យ និងប្រព័ន្ធប្រកាសឱ្យដឹងមុន (EWS) នៅតែរាយប៉ាយក្នុងថ្នាលផ្សព្វផ្សាយបច្ចេកវិទ្យាផ្សេងៗគ្នា ហើយការតាមដានជាក់លាក់អំពីរលកកម្តៅនៅខ្វះខាតនៅឡើយ។ ការពង្រឹងការចែករំលែកទិន្នន័យ ការធ្វើសុខដុមនីយកម្មសារជូនដំណឹង និងការពង្រីកការយល់ដឹងជាសាធារណៈ អាចជួយឱ្យសហគមន៍ត្រៀមលក្ខណៈឆ្លើយតបនឹងរលកកម្តៅកាន់តែមានប្រសិទ្ធភាព។ ជាមួយគ្នានេះការកសាងសមត្ថភាពពាក់ព័ន្ធនឹងផលប៉ះពាល់នៃរលកកម្តៅ ត្រូវផ្តោតលើបុគ្គលិកផ្នែកសុខភាពផងដែរ។

ហិរញ្ញវត្ថុ៖ ការត្រៀមលក្ខណៈឆ្លើយតបទឹងរលកកម្តៅ គឺជាប្រធានបទជាសកល ហើយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា កំពុងរៀបចំបន្ទាំហិរញ្ញប្បទានអាកាសធាតុឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងការបង្ការទុកជាមុន។ ការពង្រឹងការរៀបចំផែនការចរិកា និងការពង្រីកលទ្ធភាពទទួលបានជម្រើសនានា ដែលមានតម្លៃសមរម្យ អាចធ្វើឱ្យប្រសើរឡើងនូវភាពធន់ទាំងកម្រិតប្រព័ន្ធ និងកម្រិតគ្រួសារ។

[13] World Bank, Climate Change Knowledge Portal (2025). URL: https://climateknowledgeportal.worldbank.org/. Date Accessed: 22 June 2025
[14] UN ESCAP, 2025. Rising Heat, Rising Risk. Policy Pathways for Regional Resilience.
[15] Roberts, Mark, Chandan Deuskar, Nicholas Jones, and Jane Park. 2023. Unlivable: What the Urban Heat Island Effect Means for East Asia's Cities. Washington DC. The World Bank.

គោលបំណង និងអភិក្រម

គម្រោងនេះ មានគោលបំណងពង្រឹងភាពធន់ទៅនឹងរលកកម្តៅខ្លាំងសម្រាប់អ្នករស់នៅក្នុងរាជធានីភ្នំពេញ តាមរយៈការរៀបចំ និងការអនុវត្តប្រព័ន្ធគ្រប់គ្រងរលកកម្តៅគ្រប់ជ្រុងជ្រោយមួយ។ គោលបំណងនេះនឹងសម្រេចបានតាមរយៈអភិក្រមដូចខាងក្រោម៖

1. **ផ្លាស់ប្តូរពីសកម្មភាពឆ្លើយតបបែបប្រតិកម្ម ទៅជាសកម្មភាពឆ្លើយតបបែបបុរេសកម្ម៖** គម្រោងនេះជួយឱ្យរាជធានីភ្នំពេញ អាចប៉ាន់ស្មានលើហានិភ័យជាមុន អាចគ្រប់គ្រងហានិភ័យបាន និងឆ្លើយតបទាន់ពេលវេលាជាប្រព័ន្ធទៅនឹងរលកកម្តៅបន្ទាប់ពីកើតឡើង។
2. **ពង្រឹងប្រព័ន្ធនានាដែលគាំពារប្រជាជន៖** គម្រោងនេះពង្រឹងស្ថាប័ន សេវានានា និងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការចាំបាច់ ដើម្បីការពារសុវត្ថិភាពគ្រួសារ និងក្រុមជនងាយរងគ្រោះ ដោយរួមបញ្ចូលនូវការទទួលបានព័ត៌មានអំពីអាកាសធាតុ ការគាំពារសង្គម និងការអភិវឌ្ឍទីក្រុង។
3. **បញ្ចូលភាពធន់ទៅនឹងរលកកម្តៅក្នុងអភិបាលកិច្ចប្រចាំថ្ងៃ៖** តាមរយៈរចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គម្រោងនេះនឹងបង្កើតគំរូរយៈពេលវែង ដែលអាចពង្រីកវិសាលភាពបានដើម្បីរៀបចំផែនការ និងការវិនិយោគក្នុងរាជធានីភ្នំពេញឱ្យកាន់តែត្រជាក់ និងមានសុវត្ថិភាពជាងមុន។

សមាសភាគស្នូល

សមាសភាគទី ១៖ ការលើកកម្ពស់ការគ្រប់គ្រងទិន្នន័យ និងការផ្សព្វផ្សាយសម្រាប់ការព្យាករណ៍ និងការតាមដានលើរលកកម្តៅ

សមាសភាគនេះផ្តោតលើការលើកកម្ពស់សមត្ថភាពក្នុងការប៉ាន់ស្មាន និងឆ្លើយតបទៅនឹងរលកកម្តៅ។ សមាសភាគនេះ បង្កើតមណ្ឌលទិន្នន័យសម្រាប់ការតាមដានមើលកម្តៅ ដើម្បីប្រមូលទិន្នន័យឧតុនិយម និងទិន្នន័យផ្កាយរណប ព្រមទាំងជួយដល់រាជធានីភ្នំពេញ ក្នុងការរៀបចំផែនការសកម្មភាពកម្តៅ (PP-HAP) លើកដំបូងរបស់ខ្លួន ដែលបញ្ជាក់ច្បាស់លាស់អំពីតួនាទី ភារកិច្ច និងពិធីសារផ្សព្វផ្សាយ។ សមាសភាគនេះក៏ដាក់បញ្ចូលបញ្ហារលកកម្តៅទៅក្នុងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ និងពង្រឹងយន្តការគាំពារសង្គម ដើម្បីឱ្យប្រព័ន្ធទាំងនោះអាចផ្តល់ការគាំទ្រជាមុនដល់គ្រួសារ និងក្រុមជនងាយរងគ្រោះ។

សមាសភាគទី ២៖ សមាហរណកម្មភាពធន់នឹងកម្តៅក្នុងសហគមន៍ តាមរយៈកិច្ចគាំពារសង្គម ដែលបន្សាំនឹងអាកាសធាតុ និងការឆ្លើយតបនឹងការកាត់បន្ថយកម្តៅ

សមាសភាគនេះផ្តោតលើការកាត់បន្ថយហានិភ័យចំពោះមុខ ដែលគ្រួសារងាយរងគ្រោះកំពុងជួបប្រទះ និងការកែលម្អគុណភាពនៃការរស់នៅក្នុងតំបន់អាទិភាព។ សមាសភាគនេះផ្តល់ការគាំទ្រដល់សហគមន៍ដូចជា ដំណោះស្រាយលើការកាត់បន្ថយកម្តៅជាមូលដ្ឋាន ទីធ្លាសាធារណៈដែលធន់នឹងកម្តៅ និងមណ្ឌលបញ្ចុះកម្តៅ ព្រមទាំងជំរុញការផ្លាស់ប្តូរឥរិយាបថ និងការយល់ដឹងអំពីការអនុវត្តប្រកបដោយសុវត្ថិភាពក្នុងកំឡុងពេលមានរលកកម្តៅខ្លាំង។ សាលារៀន គ្លីនិកសុខភាព និងមូលដ្ឋានសុខាភិបាល រួមទាំងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងៗទៀតនឹងត្រូវបានកែលម្អ តាមរយៈដំណោះស្រាយតាមបែបធម្មជាតិ និងការប្រើប្រាស់ថាមពលត្រជាក់ប្រកបដោយប្រសិទ្ធភាព ស្របពេលដែលសមត្ថភាពក្នុងមូលដ្ឋានត្រូវបានពង្រឹងលើការរៀបចំសំណង់អគារដែលឆ្លើយតបនឹងអាកាសធាតុ។

សមាសភាគទី ៣៖ ការផ្តល់ហិរញ្ញប្បទានឆ្លើយតបនឹងហានិភ័យអាកាសធាតុ សម្រាប់ភាពធន់នឹងកម្តៅក្នុងទីក្រុងប្រកបដោយចីរភាព

សមាសភាគនេះផ្តោតលើការគាំទ្រការផ្លាស់ប្តូរពីការគ្រប់គ្រងវិបត្តិបែបប្រតិកម្ម ទៅជាការរៀបចំផែនការ និងការវិនិយោគបែបបុរេសកម្ម។ សមាសភាគនេះបានសាកល្បងយន្តការហិរញ្ញប្បទានផ្អែកលើការព្យាករណ៍ (FbF) លើកដំបូងរបស់កម្ពុជា សម្រាប់ការកាត់បន្ថយរលកកម្តៅ និងពង្រឹងសមត្ថភាពរបស់រដ្ឋបាលមូលដ្ឋានក្នុងការដាក់បញ្ចូលវិការឆ្លើយតបនឹងអាកាសធាតុ និងការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធធន់នឹងកម្តៅរយៈពេលវែង។ សមាសភាគនេះក៏លើកកម្ពស់ភាពជាដៃគូហិរញ្ញប្បទានពហុភាគី ដើម្បីធានាឱ្យមានការវិនិយោគប្រកបដោយចីរភាពលើភាពធន់នឹងកម្តៅនៅក្នុងទីក្រុងផងដែរ។

លទ្ធផលរំពឹងទុក និងការជះឥទ្ធិពល

លទ្ធផលរយៈពេលខ្លី *(នៅពេលបញ្ចប់គម្រោង)*

- **ការលើកកម្ពស់ការត្រៀមលក្ខណៈជាមុន និងការសម្របសម្រួល៖** ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសំខាន់ៗ សាកល្បង និងកែលម្អនីតិវិធីនៃការតាមដានកម្តៅ ការជូនដំណឹងជាមុន និងការឆ្លើយតបតាមរយៈប្រព័ន្ធសាកល្បង។
- **ការគាំទ្រចំគោលដៅដល់ក្រុមជនងាយរងគ្រោះ៖** សហគមន៍ដែលត្រូវបានជ្រើសរើសទទួលបានអត្ថប្រយោជន៍ពីដំណោះស្រាយនៃការអនុវត្តជាក់ស្តែងដោយផ្តោតអាទិភាពលើការកាត់បន្ថយកម្តៅ ការកែលម្អទីតាំងសាធារណៈ និងទីធ្លាសហគមន៍។

លទ្ធផលរយៈពេលវែង *(ក្រោយបញ្ចប់គម្រោង)*

- **មូលដ្ឋានកាន់តែរឹងមាំសម្រាប់ការគ្រប់គ្រងកម្តៅទូទាំងទីក្រុង៖** មេរៀនដែលទទួលបានពីការអនុវត្តសាកល្បង នឹងផ្តល់អនុសាសន៍ដល់ការរៀបចំនូវយុទ្ធសាស្ត្រគ្រប់គ្រងរលកកម្តៅ ដែលធ្វើឱ្យកាន់តែប្រសើរឡើងនៅក្នុងរាជធានីភ្នំពេញ។
- **ការដាក់បញ្ចូលភាពធន់នឹងរលកកម្តៅកាន់តែល្អប្រសើរឡើងទៅក្នុងការរៀបចំផែនការ៖** តួអង្គអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដាក់បញ្ចូលការគិតគូរអំពីបញ្ហាកម្តៅ ទៅក្នុងការគាំពារសង្គម ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេចក្តីសម្រេចនានាលើការវិនិយោគនៅមូលដ្ឋាន។

ការជះឥទ្ធិពលទូលំទូលាយ *(សមិទ្ធផលក្រោយបញ្ចប់គម្រោង)*

- **បានកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងរលកកម្តៅសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ** ជាពិសេសក្នុងចំណោមក្រុមជនងាយរងគ្រោះ។
- **បានជាគំរូម៉ូឌែល ដែលអាចអនុវត្តសម្រាប់ការពង្រីកភាពធន់នឹងរលកកម្តៅ** ដោយផ្តល់ជាកស្តុតាងឧបករណ៍ និងយន្តការហិរញ្ញប្បទាន ដែលមេរៀនបទពិសោធល្អៗ សម្រាប់យកទៅអនុវត្តនៅតំបន់ទីក្រុងផ្សេងទៀតនៃប្រទេសកម្ពុជា។

អភិក្រមគាំពារសង្គមចំពោះរលកកម្តៅ

ប្រព័ន្ធគាំពារសង្គមអាចដើរតួនាទីយ៉ាងច្រើនក្នុងការជួយដល់គ្រួសារ និងសហគមន៍ទប់ទល់នឹងរលកកម្តៅខ្លាំង។ ឧទាហរណ៍ ផែនការសកម្មភាពឆ្លើយតបនឹងកម្តៅរបស់ទីក្រុងអាម៉េដាបាដ (ប្រទេសឥណ្ឌា)[16] ផ្តោតអាទិភាពលើក្រុមជនងាយរងគ្រោះ រួមមានមនុស្សវ័យចាស់ កុមារ អ្នកធ្វើការងារនៅក្រៅអគារ និងគ្រួសារដែលមានប្រាក់ចំណូលទាប ហើយបានរួមចំណែកកាត់បន្ថយយ៉ាងច្រើននូវអត្រាស្លាប់បាត់បង់ជីវិត ដែលពាក់ព័ន្ធនឹងកម្តៅ។ ផែនការនេះរួមបញ្ចូលនូវ ការប្រកាសអាសន្នឱ្យដឹងមុន ការចុះអប់រំផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋាន និងការកំណត់ទីតាំងសម្រាប់ការកាត់បន្ថយកម្តៅ ហើយចាប់តាំងពីពេលនោះមក ត្រូវបានយកទៅអនុវត្តជាបន្តបន្ទាប់នៅក្នុងទីក្រុងជាង ៣០ ផ្សេងទៀតក្នុងប្រទេសឥណ្ឌា។ នៅប្រទេសបង់ក្លាដែស[17] កាកបាទក្រហមបង់ក្លាដែសបានធ្វើការជាមួយរដ្ឋាភិបាល សាកល្បងអនុវត្តការផ្តល់ប្រាក់បន្ថែមជាមុន (anticipatory cash top-ups) តាមរយៈកម្មវិធីគាំពារសង្គមដែលមានស្រាប់ ដូចជា ប្រាក់ឧបត្ថម្ភជនចាស់ជរា ដែលបង្ហាញពីរបៀបផ្ទេរប្រាក់តាមកាបូបលុយអេឡិចត្រូនិកនៅមុនពេលរលកកម្តៅមកដល់ ដែលជាការរួមចំណែកផ្តល់ការគាំទ្រយ៉ាងឆាប់រហ័សដល់គ្រួសារងាយរងគ្រោះ។ ផ្អែកលើបទពិសោធទាំងនេះ ប្រព័ន្ធគាំពារសង្គមអាចពិចារណា និងអនុវត្តតាមវិធានការមួយចំនួនដូចជា៖

- **ផ្តល់សាច់ប្រាក់ងាយស្រួល និងឆាប់រហ័ស** តាមរយៈការផ្ទេរសាច់ប្រាក់ ដែលអនុញ្ញាតឱ្យគ្រួសារ មានលទ្ធភាពទិញទឹក ថ្នាំពេទ្យ មធ្យោបាយកាត់បន្ថយកម្តៅ និងទទួលបានកញ្ចប់សម្ភារៈកាត់បន្ថយកម្តៅ ឬអាចទៅកាន់ទីតាំងផ្តល់ជាតិទឹក/ទីតាំងកាត់បន្ថយកម្តៅ នៅក្នុងអំឡុងពេលមានរលកកម្តៅ។
- **ការពារកម្មករនិយោជិត** តាមរយៈការកែសម្រួលគម្រោង កម្មវិធី ទីតាំងការងារ ដើម្បីកាត់បន្ថយការប្រឈមនឹងរលកកម្តៅ (ឧទាហរណ៍ ការកាត់បន្ថយវេនម៉ោងធ្វើការ ការរៀបចំកន្លែងធ្វើការដែលមានម្លប់ ការសម្រាកដើម្បីទទួលទានទឹក)។
- **ពង្រឹងការត្រៀមលក្ខណៈជាមុន** តាមរយៈការតភ្ជាប់ប្រព័ន្ធប្រកាសអាសន្នឱ្យដឹងមុនទៅនឹងប្រព័ន្ធជាតិគាំពារសង្គម និងការផ្តល់សាច់ប្រាក់មុន ឬសេវាត្រៀមបម្រុងឆ្លើយតបនឹងរលកកម្តៅ។
- **គាំទ្រដល់ការចុះអប់រំសុខភាពដល់មូលដ្ឋាន** តាមរយៈការសម្របសម្រួលជាមួយវិស័យសុខាភិបាល សម្រាប់ការលើកកម្ពស់ការយល់ដឹង ការបញ្ជូនអ្នកជំងឺទៅទទួលសេវាសុខភាព និងការតាមដានហានិភ័យពាក់ព័ន្ធនឹងរលកកម្តៅ។
- **ធានានិរន្តរភាពនៃប្រាក់ចំណូល និងការថែទាំ** សម្រាប់ប្រជាជនងាយរងគ្រោះក្នុងអំឡុងពេល និងក្រោយពេលមានព្រឹត្តិការណ៍រលកកម្តៅខ្លាំង។
- **កែសម្រួលការអនុវត្តកម្មវិធី** តាមរយៈការអនុវត្តវិធានការនានាឆ្លើយតបនឹងរលកកម្តៅ ដូចជា ការផ្លាស់ប្តូរកាលវិភាគបើកសាច់ប្រាក់ ឬការបើកផ្តល់សាច់ប្រាក់បន្ថែមដោយគិតគូរពីរលកកម្តៅ។

ភាពជាដៃគូ និងការអនុវត្ត

គម្រោងនេះ នឹងត្រូវអនុវត្តដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប.) ដោយមាន GIZ ជាដៃគូប្រតិបត្តិក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ និងភ្នាក់ងារបច្ចេកទេសដែលពាក់ព័ន្ធ។

លេខាធិការដ្ឋាន គ.ជ.អ.ប. (NCDDs) ដើរតួជាស្ថាប័នដឹកនាំ សម្របសម្រួល និងជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងធ្វើការសម្របសម្រួលការអនុវត្តជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា។ ក្នុងនាមជាស្ថាប័នថ្នាក់ជាតិ ដែលមានបទពិសោធគ្រប់គ្រាន់ក្នុងការគ្រប់គ្រងកម្មវិធីកំណែទម្រង់ រឹមជ្ឈការ និងវិសហមជ្ឈការ និងពហុភាគីពាក់ព័ន្ធ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងត្រួតពិនិត្យការងារគម្រោងធានាឱ្យមានភាពបន្សឹគ្នាជាមួយនឹងប្រព័ន្ធនានានៅថ្នាក់ជាតិ និងជួយសម្រួលការសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នៅគ្រប់កម្រិតទាំងអស់។ អង្គភាពគ្រប់គ្រងគម្រោងមួយដាច់ដោយឡែកនៃលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃ ធានាគុណភាព និងការធ្វើរបាយការណ៍ ដែលទទួលបានការគាំទ្រពីគណៈកម្មាធិការដឹកនាំគម្រោងថ្នាក់ជាតិ ដោយផ្តល់ការណែនាំជាយុទ្ធសាស្ត្រ និងការត្រួតពិនិត្យ។

GIZ ដើរតួជាអង្គភាពប្រតិបត្តិទីពីរ និងទទួលខុសត្រូវលើការអនុវត្តសមាសភាគដែលពាក់ព័ន្ធនឹងភាពធន់របស់សហគមន៍ ការគាំពារសង្គម និងការវិនិយោគសាធារណៈដែលឆ្លើយតបនឹងអាកាសធាតុ។ GIZ នឹងគ្រប់គ្រងចំណែកចរិភាគគម្រោងរបស់ខ្លួន និងសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នដៃគូនៃរាជរដ្ឋាភិបាល ព្រមទាំងគាំទ្រដល់ការពិនិត្យតាមដាន ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រផ្នែកបច្ចេកទេស។

ការអនុវត្តនឹងត្រូវធ្វើឡើងក្រោមកិច្ចសហការជាមួយក្រសួង ស្ថាប័នតាមវិស័យ និងភ្នាក់ងារជំនាញ។ រចនាសម្ព័ន្ធនៃកិច្ចសហការនេះធានាថា គម្រោងនឹងជួយពង្រឹងប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានស្រាប់ លើកកម្ពស់ភាពជាម្ចាស់រួមគ្នា និងកសាងមូលដ្ឋានគ្រឹះសម្រាប់ការពង្រីកវិសាលភាពនាពេលអនាគត។

	ចំណុចផ្តោតសំខាន់	អង្គភាពដឹកនាំ	ដៃគូសំខាន់ៗ
សមាសភាគទី ១	ការគ្រប់គ្រង និងការផ្សព្វផ្សាយទិន្នន័យនៃការតាមដានលើរលកកម្តៅ	GIZ, NCDDs	MoWRAM ដោយសហការជាមួយ RUPP
	ការគ្រប់គ្រងហានិភ័យរលកកម្តៅ សម្រាប់អ្នករស់នៅរាជធានីភ្នំពេញ តាមរយៈការរៀបចំផែនការសកម្មភាពកម្តៅនៅរាជធានីភ្នំពេញ (PP-HAP)		NCDM, MoWRAM/ក្រុមការងារ CREWS, PPCH, MoH
សមាសភាគទី ២	វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់សហគមន៍ងាយរងគ្រោះ	GIZ	PPCH, MoH, MoE
	ហេដ្ឋារចនាសម្ព័ន្ធសង្គមសម្រាប់រលកកម្តៅ និងការសាងសង់អគារដែលធន់នឹងកម្តៅ តាមរយៈការកសាងសមត្ថភាព		MoLMUPC និង PPCH
សមាសភាគទី ៣	យន្តការផ្តល់ហិរញ្ញប្បទានផ្អែកលើការព្យាករណ៍ (FbF) សម្រាប់ការឆ្លើយតបនឹងរលកកម្តៅបែបបុរេសកម្ម	NCDDs	MEF, PPCH, MoH
	ហិរញ្ញប្បទានអាកាសធាតុ ត្រូវបានដាក់បញ្ចូលទៅក្នុងថវិកា និងកម្មវិធីអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធធន់នឹងកម្តៅ		PPCH

[16] NRDC, 2019. URL: https://www.preventionweb.net/news/india-new-evidence-shows-pioneering-heat-action-plan-helps-millions-avoid-killer-heat
[17] IFRC, 2023. URL: https://heathealth.info/wp-content/uploads/EAP_Heatwave_Bangladesh.pdf

នវានុវត្តន៍ និងនិរន្តរភាព

នវានុវត្តន៍

គម្រោងនេះទទឹងសាកល្បងយន្តការហិរញ្ញប្បទានផ្អែកលើការព្យាករណ៍ (FbF) លើកដំបូងរបស់កម្ពុជា សម្រាប់ការឆ្លើយតបទឹងរលកកម្តៅបែបបុរេសកម្ម។ ដោយសារកម្តៅច្រើនតែត្រូវបានគេចាត់ទុកជាឃាតករលាក់មុខ ដែលបង្កឱ្យមានការឈឺថ្កាត់ ការស្លាប់បាត់បង់ជីវិត និងការខាតបង់ផលិតភាពកាន់តែច្រើនឡើង ដោយពុំអាចមើលឃើញជាក់ស្តែងដូចមុខសញ្ញាគ្រោះថ្នាក់ផ្សេងទៀតឡើយ។ គម្រោងនេះ នឹងដាក់ឱ្យប្រើប្រាស់ឧបករណ៍ថ្មីៗ ដើម្បីរកឱ្យឃើញត្រឹមលក្ខណៈជាមុន និងកាត់បន្ថយផលជះទាំងនេះមុនពេលវិវត្តន៍ទៅរកសភាពធ្ងន់ធ្ងរ។ តាមរយៈការដាក់បញ្ចូលការព្យាករណ៍រលកកម្តៅ មណ្ឌលកាត់បន្ថយកម្តៅបណ្តោះអាសន្ន និងហិរញ្ញប្បទានផ្អែកលើការព្យាករណ៍ គម្រោងនេះផ្តល់នូវគំរូម៉ូឌែល ដែលអាចយកទៅអនុវត្តបន្តបាន សម្រាប់ទីក្រុងនានានៅអាស៊ីអាគ្នេយ៍ដែលប្រឈមនឹងបញ្ហាស្រដៀងគ្នានៃភាពតានតឹងដោយសាររលកកម្តៅ។

ការទាញយកប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមសម្រាប់ការគ្រប់គ្រងរលកកម្តៅ គឺជាធាតុផ្សំដ៏ថ្មីស្រឡាងមួយ ព្រោះវាអាចឱ្យការគាំទ្រគ្របដណ្តប់ដល់គ្រួសារងាយរងគ្រោះបានយ៉ាងឆាប់រហ័ស និងប្រកបដោយសមធម៌ តាមរយៈប្រព័ន្ធរបស់រាជរដ្ឋាភិបាលដែលបានរៀបចំ និងបង្កើតឡើង។ ការដោះស្រាយការកាត់បន្ថយរលកកម្តៅដោយប្រើប្រាស់បច្ចេកវិទ្យាកម្រិតទាប ការកែលម្អហេដ្ឋារចនាសម្ព័ន្ធសង្គម និងការគាំពារសង្គមដែលមានភាពបត់បែន គឺជាវិធានថ្មីមួយសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ជំនួយឥតសំណងរបស់ GCF អាចជួយកាត់បន្ថយហានិភ័យនៃអតិក្រមទាំងនេះ និងបង្កើតជាមូលដ្ឋានភស្តុតាងដែលចាំបាច់សម្រាប់ការកៀរគរការវិនិយោគនាពេលអនាគតពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។

និរន្តរភាព និងយុទ្ធសាស្ត្រចាកចេញ

គម្រោងនេះត្រូវបានរៀបចំឡើងដើម្បីបង្កើតផលជះយូរអង្វែង ក្រោយបញ្ចប់ការអនុវត្តគម្រោង។ តាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន និងការបញ្ជ្រាបផែនការសកម្មភាពកម្តៅនៅរាជធានីភ្នំពេញ (PP-HAP) ទៅក្នុងប្រព័ន្ធផែនការនៃរាជរដ្ឋាភិបាល។ គម្រោងនេះធានាថា ការគ្រប់គ្រងរលកកម្តៅនឹងនៅបន្តនិរន្តភាព ដែលជាផ្នែកមួយមិនអាចខ្វះបានក្នុងការផ្តល់សេវាសាធារណៈ។ មូលដ្ឋានគ្រឹះនេះក៏អាចឱ្យមានការពង្រីកវិសាលភាពអនុត្តន៍នាពេលអនាគតទៅកាន់តំបន់ទីក្រុងផ្សេងៗទៀតនៃប្រទេសកម្ពុជាផងដែរ និងបំពេញបន្ថែមលើគំនិតផ្តួចផ្តើមដែលទទួលបានពីការអនុវត្តសាកល្បងនៅខេត្តសៀមរាប ដែលដឹកនាំដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងអង្គការយូនីសេហ្វ (UNICEF) លើវិស័យអប់រំ និងទេសចរណ៍។

មណ្ឌលកាត់បន្ថយរលកកម្តៅបណ្តោះអាសន្ននៅកម្រិតសហគមន៍ក្នុងសមាសភាគទី ២ នឹងជំរុញឱ្យមានភាពជាម្ចាស់ដ៏រឹងមាំនៅមូលដ្ឋាន។ ការជ្រើសរើសទីតាំង និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នឹងផ្អែកតាមការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយជាមួយសហគមន៍ ដើម្បីធានាបាននូវការឆ្លើយតបតាមតម្រូវការដាក់ស្តែងប្រកបដោយប្រសិទ្ធភាព។ ការទទួលខុសត្រូវលើការថែទាំ នឹងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយជាតិ ដើម្បីគាំទ្រដល់ការដំណើរការយូរអង្វែង និងមាននិរន្តរភាព។

អក្សរកាត់

ADB	ធនាគារអភិវឌ្ឍន៍អាស៊ី
CREWS	គម្រោងហានិភ័យអាកាសធាតុ និងប្រព័ន្ធប្រកាសឱ្យដឹងមុន
EWS	ប្រព័ន្ធប្រកាសឱ្យដឹងមុន
FbF	ហិរញ្ញប្បទានផ្អែកលើការព្យាករណ៍
GCF	មូលនិធិអាកាសធាតុបៃតង
GIZ	កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
LDC	ប្រទេសមានការអភិវឌ្ឍតិចតួច
MEF	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MoE	ក្រសួងបរិស្ថាន
MoH	ក្រសួងសុខាភិបាល
MoLMUPC	ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
MoWRAM	ក្រសួងធនធានទឹក និងឧតុនិយម
NCDDs	លេខាធិការដ្ឋាន គ.ជ.អ.ប.
NCDM	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
PPCH	សាលារាជធានីភ្នំពេញ
PP-HAP	ផែនការសកម្មភាពកម្តៅរាជធានីភ្នំពេញ
RCP	គន្លងកំហាប់តំណាង (Representative Concentration Pathway)
RUPP	សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
UHI	កម្តៅតំបន់ទីក្រុង (Urban Heat Island)
UNICEF	មូលនិធិសហប្រជាជាតិសម្រាប់កុមារ (យូនីសេហ្វ)

ព័ត៌មានបោះពុម្ពផ្សាយ

បោះពុម្ពផ្សាយដោយ៖
លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប.)

អាសយដ្ឋាន៖
ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ (អគារ V)
មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

បោះពុម្ព៖
ខែធ្នូ ឆ្នាំ២០២៥

រចនាដោយ៖
អ៊ាន មុនីលក្ខណ៍
រាជធានីភ្នំពេញ

កម្មសិទ្ធិរូបថត៖
GIZ/Roman Koenig

រៀបចំ និងគាំទ្រដោយ៖
លេខាធិការដ្ឋាន គ.ជ.អ.ប. និងគម្រោងលើកកម្ពស់គាំពារសង្គម និងសុខភាព ដំណាក់កាលទី ២ (ISPH II) របស់ GIZ

សេចក្តីប្រកាស៖
ឯកសារនេះរៀបចំឡើងដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រោមការគាំទ្រពីគម្រោង ISPH II របស់ GIZ សម្រាប់ជាឯកសារទស្សនទានដាក់ជូន GCF ស្តីពី «ការពង្រឹងភាពធន់ទៅនឹងរលកកម្តៅខ្លាំងនៅរាជធានីភ្នំពេញ៖ ធានាថាសហគមន៍ក្នុងរាជធានី មានសុវត្ថិភាព មានសុខភាពល្អ និងប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា»។ ឯកសារនេះត្រូវបានចេញផ្សាយសម្រាប់ភាគីដែលផ្តល់ការអនុញ្ញាតឱ្យធ្វើការសិក្សាស្រាវជ្រាវ និងសម្រាប់គោលបំណងជាក់លាក់ពាក់ព័ន្ធនឹងគម្រោងខាងលើតែប៉ុណ្ណោះ។ យើងមិនទទួលខុសត្រូវចំពោះផលវិបាកណាមួយដែលកើតចេញពីការយកឯកសារនេះទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងឡើង។ ឯកសារនេះមានព័ត៌មានសម្ងាត់ និងកម្មសិទ្ធិបញ្ញាផ្តាច់មុខ និងមិនគួរត្រូវបានយកទៅបង្ហាញដល់ភាគីដទៃទៀតដោយគ្មានការអនុញ្ញាតពីយើងខ្ញុំឡើយ។ មតិយោបល់ដែលបានបង្ហាញក្នុងរបាយការណ៍នេះ គឺជាមតិរបស់បុគ្គលិក និងសហការី NCDD-S និង GIZ ដែលបានចាត់តាំងសម្រាប់ការសិក្សានេះ នឹងមិនឆ្លុះបញ្ចាំងពីទស្សនៈភាគីណាផ្សេងទៀតឡើយ។